ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ERIKSHJÄLPEN

# អនុស្សរណៈនៃការយោគយល់

## រវាង

## គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស

## និង

## អង្គការដៃគូអភិវឌ្ឍន៍ អេរិក្ស

## ស្តីពី

## សកម្មភាពបង្ការទប់ស្កាត់ ប្រយុទ្ធប្រឆាំងរាល់ទម្រង់នៃការជួញដូរមនុស្ស និងការកេងប្រវ័ញ្ចលើកុមារ

# បុព្វកថា

**ដោយហេតុថា៖** គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) មានបំណងសហការជាមួយ អង្គការដៃគូអភិវឌ្ឍន៍ អេរិក្ស (ដែលហៅកាត់ថា ERIKS) ដែលបាននិងកំពុងគាំទ្រអង្គការដៃគូក្នុងស្រុកចំនួន៦ (ដូចមានភ្ជាប់ក្នុងឧបសម្ព័ន្ធ១/២) លើការងារមនុស្សធម៌នៅក្នុងព្រះរាជាណាចក្រកម្ពុជា ដើម្បី រួមចំណែកលើកកម្ពស់សុខុមាលភាពសង្គមតាមរយៈកិច្ចការពារសិទ្ធិកុមារឱ្យទទួលបានការអប់រំ សេវាសុខភាព ព្រមទាំងបង្ការទប់ស្កាត់ និងការពារកុមារពីអំពើជួញដូរ អំពើរំលោភបំពានផ្លូវភេទ និងអំពើកេងប្រវ័ញ្ចគ្រប់ទម្រង់។

**ដោយហេតុថា៖** ដើម្បីធានាប្រសិទ្ធភាពការងារបង្ការទប់ស្កាត់ ប្រយុទ្ធប្រឆាំងរាល់ទម្រង់ នៃការកេងប្រវ័ញ្ចរំលោភបំពានផ្លូវភេទ និងអំពើជួញដូរមនុស្សតាមការរំពឹងទុក សកម្មភាពទាំងឡាយនឹងត្រូវធ្វើឡើងតាមរយៈយន្តការជាតិ និងថ្នាក់ក្រោមជាតិ ផ្អែកលើផែនការយុទ្ធសាស្ត្រជាតិរបស់ គ.ជ.ប.ជ ច្បាប់ និងគោលនយោបាយជាតិ និងអន្តរជាតិ ព្រមទាំងបទដ្ឋានគតិយុត្តពាក់ព័ន្ធនានា។

## ប្រការ១

## គោលបំណង នៃអនុស្សរណៈ

ពង្រឹងកិច្ចសហប្រតិបត្តិការរវាង គ.ជ.ប.ជ និងអង្គការ ERIKS ព្រមទាំងដៃគូពាក់ព័ន្ធដើម្បីលើកកម្ពស់ និងការពារសិទ្ធិកុមារពីរាល់ទម្រង់នៃអំពើជួញដូរមនុស្ស និងអំពើកេងប្រវ័ញ្ចផ្សេងទៀត។

## ប្រការ២

## ការទទួលខុសត្រូវរបស់គណៈកម្មាធិការជាតិ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សមានភារកិច្ច៖

១. អនុញ្ញាតឱ្យអង្គការ ERIKS និងដៃគូបំពេញការងាររបស់ខ្លួនដោយអនុវត្តទៅតាមគោលការណ៍ ច្បាប់ លិខិតបទដ្ឋានគតិយុត្ត នៃព្រះរាជាណាចក្រកម្ពុជា។

២. ដាក់ចេញនូវគោលការណ៍ណែនាំ និងអនុញ្ញាតឱ្យលេខាធិការដ្ឋាន គ.រ.ប.ជ និងគ.ខ.ប.ជ រាជធានី/ខេត្តពាក់ព័ន្ធសហការជាមួយដៃគូអង្គការ ERIKS ដែលធ្វើសកម្មភាពនៅក្នុងភូមិសាស្ត្ររបស់ខ្លួន។

៣. អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ សម្របសម្រួលទទួលព័ត៌មាន និងរបាយការណ៍ពីអង្គការERIKS ស្ដីពីសកម្មភាព លទ្ធផល និងបទពិសោធន៍ ឬភាពប្រឈមនានាដែលត្រូវរួមគ្នាដោះស្រាយ។

៤.សហការជាមួយអង្គការ ERIKS រៀបចំកិច្ចប្រជុំបច្ចេកទេស និងផ្សព្វផ្សាយអំពីការអនុវត្តអនុស្សរណៈដល់ដៃគូរបស់ ERIKS ជាមួយនឹងលេខាធិការដ្ឋាន នៃគ.រ.ប.ជ និងគ.ខ.ប.ជ។

៥. អនុញ្ញាតឱ្យ ERIKS និងអង្គការដៃគូចូលរួមក្នុងកិច្ចប្រជុំពិគ្រោះយោបល់រៀបចំផែនការជាតិ គោលនយោបាយ ឬបទដ្ឋានចាំបាច់នានាដែលពាក់ព័ន្ធនឹងការទទួលខុសត្រូវរបស់ERIKS។

៦. រៀបចំកិច្ចប្រជុំត្រីមាស និងកិច្ចប្រជុំវិសាមញ្ញតាមការចាំបាច់ ដើម្បីតាមដានភាពរីកចម្រើនក្នុងការអនុវត្តគម្រោង ភាពប្រឈមដែលត្រូវដោះស្រាយ និងចែករំលែកនូវបទពិសោធន៍ដែលទទួលបានទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។

## ប្រការ៣
## ការទទួលខុសត្រូវរបស់អង្គការ ERIKS

១. គ្រប់គ្រងថវិកាបានមកពីសប្បុរសជន នៅការិយាល័យកណ្តាលរបស់អង្គការនៅប្រទេសស៊ុយអែត អនុវត្តសកម្មភាពរបស់គម្រោងឱ្យមានប្រសិទ្ធភាពចំតាមគោលដៅ និងត្រូវគោរពឱ្យបានខ្ជាប់ខ្ជួននូវច្បាប់ និងបទបញ្ញត្តិទាំងឡាយរបស់ព្រះរាជាណាចក្រកម្ពុជា និងមិនអនុញ្ញាតឱ្យភ្នាក់ងាររបស់ខ្លួន មានការចូលរួមនូវរាល់សកម្មភាពទាំងឡាយណាដែលអាចប៉ះពាល់ដល់សុវត្ថិភាព ស្ថិរភាព និងសណ្តាប់ធ្នាប់សង្គម ឬសកម្មភាពដទៃទៀតដែលអាចបង្កអន្តរាយដល់សន្តិសុខជាតិ ឯកភាពជាតិ វប្បធម៌ និងប្រពៃណីរបស់ប្រជាជនកម្ពុជា។

២. ប្រតិបត្តិនូវរាល់សកម្មភាពមនុស្សធម៌ជួយដល់កុមាររងគ្រោះ និងងាយរងគ្រោះស្របតាមផែនការសកម្មភាព និងគោលនយោបាយរបស់ខ្លួន និងអនុលោមតាមខ្លឹមសារនៃអនុស្សរណៈដោយប្រកាន់ខ្ជាប់នូវគោលការណ៍ នៃកិច្ចសហប្រតិបត្តិការ។

៣. ពង្រឹងភាពជាដៃគូជាមួយអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ និងលេខាធិការដ្ឋាន គ.រ.ប.ជ/គ.ខ.ប.ជ ដើម្បីសម្របសម្រួលដល់ការផ្លាស់ប្តូរព័ត៌មានរវាងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិស្តីពីសកម្មភាពដែលបានអនុវត្ត និងទិសដៅបន្ត។

៤. ចូលរួមតែសកម្មភាពបង្ការទប់ស្កាត់ ការកេងប្រវ័ញ្ចផ្លូវភេទលើកុមារ ដែលបានទទួលការសហការជាមួយ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដើម្បីជាប្រយោជន៍ជួយដល់កុមាររងគ្រោះ និងងាយរងគ្រោះតែប៉ុណ្ណោះ។ ចៀសវាងដាច់ខាតពីសកម្មភាពបង្កើតប្រាក់ចំណូល និងចំណេញ ព្រមទាំងសកម្មភាពនយោបាយ ដែលមិនបម្រើដល់គោលដៅមនុស្សធម៌ និងការជួយដល់កុមាររងគ្រោះ និងងាយរងគ្រោះដូចដែលអង្គការអភិវឌ្ឍន៍ដៃគូអេរិក្សបានប្រកាស។

៥. ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរដល់ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ស្តីពីការផ្លាស់ប្តូរណាមួយទាក់ទងនឹងអាសយដ្ឋាន អ្នកតំណាង និងនាយកគម្រោងដែលបានចាត់តាំង។

៦. រៀបចំគម្រោងផែនការរួមគ្នាដើម្បីអនុវត្តអនុស្សរណៈ និងជំរុញការអនុវត្តឱ្យមានប្រសិទ្ធភាព។

៧. ប្រមូលទិន្នន័យ និងរបាយការណ៍ប្រចាំឆ្នាំស្តីពីភាពរីកចម្រើនក្នុងការអនុវត្តសកម្មភាពដែលបានគ្រោងទុកពីអង្គការដៃគូ ដើម្បីបូកសរុប និងផ្ញើជូនអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ។

៨. រៀបចំកិច្ចប្រជុំបូកសរុបប្រចាំឆ្នាំស្តីពីលទ្ធផលការងារអនុវត្តអនុស្សរណៈ វាយតម្លៃ និងលើកទិសដៅសម្រាប់អនុវត្តនៅឆ្នាំបន្ទាប់។

## ប្រការ៤

## ការដោះស្រាយវិវាទ

រាល់វិវាទដែលអាចកើតឡើងពាក់ព័ន្ធនឹងការបកស្រាយ ឬការអនុវត្តអនុស្សរណៈយោគយល់នេះ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអង្គការដៃគូអភិវឌ្ឍន៍អេរិក្ស ត្រូវដោះស្រាយតាមរយៈការចរចាដោយសន្តិវិធីរវាងភាគីទាំងពីរ ។

## ប្រការ ៥

## អវសានប្បញ្ញត្តិ

អនុស្សរណៈយោគយល់នេះ ចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខា និងមានសុពលភាពរយៈពេល ៣(បី)ឆ្នាំ ហើយអាចបន្តសុពលភាពបានទៀតដោយមានការយល់ព្រមពីភាគីទាំងពីរ។

ភាគីម្ខាងអាចជូនដំណឹងទៅភាគីម្ខាងទៀតជាលាយលក្ខណ៍អក្សរ ក្នុងពេលណាក៏បានប្រសិនបើខ្លួនមានបំណងបញ្ចប់អនុស្សរណៈយោគយល់នេះ។ ក្នុងករណីនេះ អនុស្សរណៈយោគយល់ នឹងត្រូវបញ្ចប់ក្នុងរយៈពេល ៦០(ហុកសិប)ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទនៃការទទួលបានការជូនដំណឹង។

អនុស្សរណៈយោគយល់នេះ ធ្វើឡើងជាពីរច្បាប់ដើម ជាភាសាខ្មែរ និងភាសាអង់គ្លេស ដែលអត្ថបទទាំងពីរភាសាមានតម្លៃស្មើគ្នា។ ក្នុងករណីមិនមានការឯកភាពគ្នាលើការបកស្រាយអត្ថបទទាំងនេះ អត្ថបទជាភាសាខ្មែរត្រូវយកជាគោល ។

ថ្ងៃ សុក្រ ១០ កើត ខែ មាឃ ឆ្នាំឆ្លូវ ត្រីស័ក ព.ស២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ២០២២

**តំណាងគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស**

អនុប្រធានអចិន្ត្រៃយ៍

**ជូ ប៊ុនអេង**

**អង្គការអភិវឌ្ឍន៍ដៃគូអេរិក្ស ប្រចាំកម្ពុជា**

អ្នកគ្រប់គ្រងប្រចាំអាស៊ី

**គេង ប៊ុនឈឿត**

# ឧបសម្ព័ន្ធ ១

## សេចក្តីបរិយាយអំពីគម្រោង

| | | |
|---|---|---|
| **ឈ្មោះស្ថាប័ន** | ៖ | អង្គការអភិវឌ្ឍន៍ដៃគូ អេរិក្ស |
| **ប្រភេទស្ថាប័ន** | ៖ | អង្គការបរទេសក្នុងស្រុក |
| លិខិតអនុញ្ញាត | ៖ | អនុស្សរណៈរវាងអង្គការ ERIKSHJALPEN និងរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី២៥ ខែមករា ឆ្នាំ២០២១ |
| **អាសយដ្ឋានៈ** | ៖ | ផ្ទះលេខ២៧ ផ្លូវលេខ ៥០៦ កែង ១៣៥ សង្កាត់ផ្សារដើមថ្កូវ ខណ្ឌចំការមន រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា |
| **លេខទូរសព្ទទំនាក់ទំនង** | ៖ | ០១២ ៦៤ ៦៤ ២៦ / ០១២ ៨៩៣ ៧៤២ |
| **អ៊ីម៉ែល** | ៖ | bunchhoeuth.keng@eriksdevelopment.org |
| **ឈ្មោះគម្រោងសកម្មភាព** | ៖ | កុមារទទួលបានការអប់រំ សេវាសុខភាព និងការការពារពីការការកេង ប្រវ័ញ្ច ការរំលោភបំពានរាល់ទម្រង់រួមទាំងផ្លូវភេទ និងការជួញដូរកុមារក្នុង គ្រប់រូបភាព ។ |
| **លេខកូដគម្រោង** | ៖ | ៨២៧៥០០-៤៧៨៩ |
| **ទីតាំងគម្រោង** | ៖ | ២៥ រាជធានី-ខេត្ត |
| **ដៃគូអនុវត្តគម្រោង** | ៖ | អង្គការចំនួនប្រាំមួយដែលមានសកម្មភាពដើម្បីកុមារ |
| **ថវិកាអនុវត្តន៍គម្រោង** | ៖ | ៣,៣៨៥,៩០០ (បីលាន បីរយសែសិបប្រាំពាន់ ប្រាំបួនរយដុល្លារសហរដ្ឋ អាម៉េរិកគត់) |
| **អ្នកផ្តល់ថវិកាគាំទ្រគម្រោង** | ៖ | សប្បុរសជននៅការិយាល័យកណ្ដាលរបស់អង្គការនៅប្រទេសស៊ុយអែត |
| **កាលបរិច្ឆេទចាប់ផ្តើម** | ៖ | ថ្ងៃទី០១ ខែមករា ឆ្នាំ២០២២ |
| **កាលបរិច្ឆេទបញ្ចប់** | ៖ | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៦ |
| **ចំនួនបុគ្គលិកខ្មែរ** | ៖ | ចំនួន ៥ នាក់ (ស្រី ២ នាក់) |
| **ចំនួនបុគ្គលិកបរទេស** | ៖ | គ្មាន |

# ឧបសម្ពន្ធ ២

## បញ្ជីឈ្មោះអង្គការដៃគូរបស់អង្គការអេរិចឡ្សន៍អេរិក្សនៅក្នុងប្រទេសកម្ពុជា

**list of ERIKS' Partners in Cambodia:**

1. **អង្គការសម្ព័ន្ធចាប់ដៃ Chab Dai Coalition**: To combat toward ending Human trafficking and all forms of abuses including providing justice, appropriate social services, and support to victims.
2. **អង្គការម្លប់ឫស្សី Mlup Russey Organisation**: To promote safe environment for children in situational care and safe transition of children from institutional care to communities and families.
3. **អង្គការពន្លឺកម្ពុជា Sunshine Cambodia Organisation:** To promote poor children access education and protection.
4. **អង្គការគាំពារភូមិយើង Kaompia Phum Yoeung**: To improve family financial stability, thereby they are able to support their children's education and protection.
5. **អង្គការប្រិយសម្ព័ន្ធគ្រីស្ទបរិស័ទកម្ពុជា Evangelical Fellowship of Cambodia:** to develop capacity of communities to take responsibility for disaster preparedness and response with child rights focused.
6. **អង្គការហេការកម្ពុជា Hagar Cambodia**: To promote justice and provide appropriate social services to child survivors from trafficking and sexual abuse.